# រឿង ភ្នំនាងកង្រី



០៨០.
៥៩

**ប្រភេទសៀវភៅនិទានរឿងព្រេងខ្មែរដោយរូបភាពសំរាប់កុមារលេខ២៦**
រៀបរៀងដោយគណៈកម្មការសង្ខេបរឿងរបស់ក្រសួងអប់រំយុវជន និងកីឡា
និងបណ្ណាល័យ **JSRC**
ឧបត្ថម្ភដោយបណ្ណាល័យ **JSRC**
បោះពុម្ពដោយរោងពុម្ព **JSRC**
ចំនួន ៣០០០ ច្បាប់
វិចិត្ររូបភាពដោយ គីម សុគន្ធ
បោះពុម្ព ខែមិនា ឆ្នាំ១៩៩៦

ការបោះពុម្ពសៀវភៅនេះ បានទទួលការអនុញ្ញាតពីក្រសួងពត៌មាន
លេខ ២៦១/៩៥ ព. ម. ប្រ. ក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៥
រក្សាសិទ្ធិ អង្គការជំនួយ សូត្តូស្ហ ជប៉ុន (**JSRC**)
ហាមថតចំលង

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីហ្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh      www.elibraryofcambodia.org

០៨០.៥៩

# បុព្វកថា

*****

ប្រភេទសៀវភៅនិទានរឿងព្រេងខ្មែរដោយរូបភាព សំរាប់កុមារ នេះ បានរៀបរៀងឡើងក្នុងគោលបំនង :

- ធ្វើអោយកុមារមានសេចក្តីសប្បាយរីករាយ
- ជួយដល់ការលូតលាស់ផ្នែកស្មារតី និងអប់រំបញ្ញារបស់កុមារ
- អោយកុមារស្គាល់វប្បធម៌របស់ខ្មែរ
- ជំនួយដល់ឪពុកម្តាយ ឬ លោកគ្រូអ្នកគ្រូ ក្នុងការនិទានរឿងផ្សេងៗ សំរាប់កុមារ

យើងខ្ញុំរង់ចាំទទួលនូវការផ្តល់មតិកែលំអ ពីមិត្តអ្នកអានទាំងអស់ ដោយសេចក្តីសោមនស្សរីករាយជាទីបំផុត ។

សូមអរគុណ !

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE
៤០៤២/៩៨



នៅឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង មានភ្នំមួយខ្ពស់ជាងគេ ។ បើមើលពីចំងាយទៅ ឃើញដូចមនុស្សដេកសណ្ដូកខ្លួន ។ នៅលើភ្នំនោះ មានរុក្ខជាតិតូច ធំដុះច្រើនដូចភ្នំឯទៀតនៅជុំវិញ នោះដែរ តែប្លែកជាងត្រង់នៅចង្កេះភ្នំនោះ មាន ម្អមដុះច្រើនណែនណាន់តាន់តាប់ ។ អ្នកស្រុក នៅជុំវិញភ្នំនោះ គេមិនបរិភោគម្អមនោះទេ ព្រោះ គេលឺចាស់ៗ ដំនាលថា ÷ ភ្នំនោះកើតពីរូបនាង កង្រីយក្ខិនីដែលជាមហេសីព្រះពុទ្ធិសែន ហើយ គេសន្មតថាម្អមនោះជារោមយោនីនៃនាងកង្រី ។



មិនតែប៉ុននោះ នៅជើងភ្នំនោះ មានត្បាល់ថ្មមួយ និងអង្រែថ្មមួយធំ តាំងពីបុរាណមក មិនដឹងជានរណាសាងទេ ។ មុនឡើងភ្នំនោះ គេមានជំនឿថា ត្រូវតែយកអង្រែបុកត្បាល់ថ្មនោះ ទើបមិនចាញ់ និងបានសុខសប្បាយ (នេះជាជំនឿរបស់អ្នកស្រុកដែលមានតាំងពីបុរាណកាល) ។





រឿងនាងកង្រី មានសេចក្ដីសង្ខេបដូចតទៅនេះ ÷ កាលពីព្រេងនាយ នៅនគរមួយ មានសេដ្ឋីម្នាក់ជាមនុស្សគ្មានកូន បាននាំប្រពន្ធទៅបន់សុំកូននៅដើមជ្រៃមួយ ។ ក្រោយពីបន់ ប្រពន្ធមានកូនដប់ពីរនាក់សុទ្ធតែស្រី ។ លុះបានកូនហើយ សេដ្ឋីធ្លាក់ខ្លួនជាអ្នកទ័លក្រ រកអាហារចិញ្ចឹមគ្មាន ក៏បររទេះដឹកកូនទាំងដប់ពីរ ទៅប្រោសចោលក្នុងព្រៃជ្រៅ ។





ក្នុងចំនោមនាងទាំងដប់ពីរ នាងបង ៗ ទាំងដប់មួយនាក់ ត្រូវគេឆ្លៀលគ្រាប់ភ្នែកទាំងសងខាង ឯនាងពៅត្រូវគេឆ្លៀលគ្រាប់ភ្នែកតែម្ខាង ដោយមកពីជាតិមុននាងបានដោតភ្នែកត្រីតែម្ខាងដែរ ។ បានសំរេចបំនងហើយ នាងសន្ធមារក៏យកគ្រាប់ភ្នែកនាងទាំងដប់ពីរ ទៅទុកក្នុងឃ្លាំងឯនគររបស់ខ្លួន អោយនាងកង្រីជាកូនថៃរក្សា ។





នាងទាំងដប់ពីរមានគភ៌គ្រប់ៗគ្នា ដោយឡែកនាងពៅមានព្រះពោធិសត្វមកចាប់ផ្ទៃ ។ ពេលដែលនាងបង ៗ កើតកូនមកភ្លាម ដោយការអត់ឃ្លានខ្លាំងពេក ម្ដាយក៏ហែកសាច់កូនចែកគ្នាស៊ីអស់ជាបន្ដបន្ទាប់ ។ ចំនែកនាងពៅ កើតកូនមកអោយឈ្មោះថា « ពុទ្ធិសែន » ហើយលាក់ទុកមិនអោយនាងបង ៗ ដឹង ។

ចំនែរកាលក្រោយមក ពុទ្ធិសែនធំពេញជំទង់ មានទេពកោសល្យខាងលេងល្បែងភ្នាល់ទាំងឡាយ រហូតបានចូលទៅលេងចត្រង្គជាមួយព្រះបាទរថសិទ្ធជាបិតា ។



នាងសន្ធមាររចាប់សង្ស័យ ។ វាក៏ប្រើអាមាត្យអោយស៊ើប ហើយដឹងថា ពុទ្ធិសែនជាកូននាងពីរដណ្ដប់ ទើបរកឧបាយកល ប្រើអោយជិះសេះនាំសំបុត្រទៅអោយនាងកង្រី ។ ក្នុងសំបុត្រមានសេចក្ដីថា « បើពុទ្ធិសែនមកដល់យប់ អោយស៊ីទាំងយប់ ដល់ថ្ងៃអោយស៊ីទាំងថ្ងៃ » ។ តែជាភ័ព្វសំនាងរបស់ពុទ្ធិសែន នៅពេលជិះសេះទៅដល់ពាក់កណ្ដាលព្រៃ ព្រះអង្គឈប់សំរាកហើយក៏ផ្ទឹលង់លក់ ។ ពេលនោះ មហាឫសីបានឃើញសំបុត្រដែលចងនៅកសេះ ។



មហាឫសីហែកសំបុត្រនោះចោល ហើយសរសេរសំបុត្រថ្មីថា « បើពុទ្ធិសែនមកដល់ពេលយប់អោយរៀបការទាំងយប់ បើមកដល់ពេលថ្ងៃអោយរៀបការទាំងថ្ងៃជាមួយនាង » ។

ពេលពុទ្ធិសែនទៅដល់នគរយក្ស នាងកង្រីបានឃើញសំបុត្រក៏រៀបការជាមួយពុទ្ធិសែនភ្លាម។ ព្រះពុទ្ធិសែន ក៏បានសោយរាជ្យនៅនគរយក្ស មិនយូរប៉ុន្មាន នាងកង្រីបានថ្វាយដំនឹងអំពីប្រស្រីភ្នែក អំពីថ្នាំសំរាប់ដាក់ភ្នែកអោយជា និងថ្នាំសំរាប់បោះទៅកើតជាសមុទ្រ ជាភ្នំបាន ។



បន្ទាប់មក ព្រះពុទ្ធិសែនក៏លួចយកថ្នាំ និងកែវភ្នែកមាតារត់ចោលនាងកង្រី ទាំងអគ្រាត្រមកនគរវិញ ។ នាងកង្រីភ្ញាក់ឡើងបាត់ស្វាមីក៏តាមរក ។ ដើម្បីកុំអោយនាងតាមទាន់ ព្រះពុទ្ធិសែនក៏បោះថ្នាំអោយកើតជាទឹកសមុទ្រឃាំងផ្លូវ ធ្វើអោយនាងកង្រីយំសោកបោកខ្លួន រហូតដល់ស្លាប់នៅពាក់កណ្តាលព្រៃ ។ ព្រះពុទ្ធិសែនមកដល់នគរវិញដោយសុវត្ថិភាព ។ ព្រះអង្គទ្រង់ដាក់ថ្នាំ និងកែវភ្នែកថ្វាយព្រះមាតា និងព្រះមាតាធំទាំងអស់អោយជាឡើងវិញ ។ ព្រះអង្គទ្រង់សំលាប់នាងសន្ធមារ ហើយទ្រង់ឡើងសោយរាជ្យជំនួសព្រះបិតាបានសុខក្សេមក្សាន្ត រហូតដល់ទ្រង់សោយព្រះទីវង្គត ៕

ចប់

